# ការសិក្សាតាមដានបន្តពីផលប៉ះពាល់នៃអង្គការកសិករទៅលើផលិតភាពស្រូវ និងផលិតកម្មសត្វចិញ្ចឹម[១]

## សេចក្តីផ្តើម

ហេតុផលសំខាន់ក្នុងការបង្កើតអង្គការកសិករ (FOs) គឺការផ្តល់សេវាទ្រទ្រង់ប្រកបដោយប្រសិទ្ធភាព និងជាសមូហភាពសម្រាប់កសិករតូចតាច ដើម្បីកាត់បន្ថយឧបសគ្គចម្បងៗ ដែលធ្វើឲ្យកិច្ចប្រឹងប្រែងផ្សេងៗ ពុំមានប្រសិទ្ធភាពក្នុងការបង្កើនផលិតភាព និងពង្រឹងសិទ្ធិអំណាចជាសមូហភាពរបស់ផលិតករខ្នាតតូច នៅក្នុងទីផ្សារធាតុចូល និងធាតុចេញ។ ផ្អែកតាមទ្រឹស្តី FOs គួរអាចពង្រឹងអំណាចចរចារបស់កសិករ និងកាត់បន្ថយចំណាយប្រតិបត្តិការ ដែលអាចជួយបង្កើនសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រ តាមការបង្កើនចំណូល និងជំរុញការអភិវឌ្ឍជនបទ និងកសិកម្មប្រកបដោយចីរភាព (Barham and Chitemi 2007; Bachke 2010)។

នៅកម្ពុជា ប្រជាជនក្រីក្រជាង ៩០% រស់នៅតំបន់ជនបទ និងពឹងផ្អែកលើកសិកម្មជាប្រភពចម្បងនៃការចិញ្ចឹមជីវិត។ វិស័យកសិកម្មកម្ពុជា មានលក្ខណៈសម្គាល់ជាការដាំដុះខ្នាតតូច៖ ប្រជាកសិករនៅជនបទប្រមាណ ៨៤% មានដីកសិកម្មតិចជាងមួយហិកតា (World Bank 2005, 2009)។ ការសិក្សាមួយចំនួនបង្ហាញថា កសិករខ្នាតតូច នឹងមិនអាចពង្រីកផលិតភាព ឬអំណាចចរចារបស់ខ្លួននៅចំពោះមុខ កសិដ្ឋានពាណិជ្ជកម្មនិងអ្នកទិញធំៗបានទេ លើកលែងតែមានបទបញ្ញត្តិច្បាប់សម្រួលឲ្យកសិករខ្នាតតូចបង្កើតជា អង្គការផលិតករនៅតាមជនបទ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត ក៏មានដំណើរការដូច្នេះដែរ (Couturier *et al.* 2006; Nou 2006; Bingen *et al.* 2003; Chirwa *et al.* 2005; Peacock *et al.* 2004; Abaru *et al.* 2006; Barham and Chitemi 2007)។

ឯកសារពាក់ព័ន្ធបង្ហាញថា ចាប់តាំងពីពេលរាជរដ្ឋាភិបាលកម្ពុជាបានលើកពីសារៈសំខាន់នៃ FOs និង តួនាទីជាយុទ្ធសាស្ត្រនៃវិស័យឯកជន ក្នុងការអភិវឌ្ឍជនបទ និងកសិកម្មមក មានការសិក្សាតិចតួចណាស់ ដែលបានពិនិត្យពីឥទ្ធិពលនៃ FO ទៅលើជីវភាពនៅជនបទ។ ការសិក្សាកន្លងមក បានព្យាយាមកំណត់ពីស្ថានភាព FOs តាមការវាយតម្លៃពី ចំនួននិងប្រភេទនៃអង្គការ, ដំណើរការចុះបញ្ជីរបស់ FO, បញ្ហាធំៗ ដែល FOs កំពុងប្រឈមមុខ, កត្តាខាងក្នុង និងក្រៅ ដែលប៉ះពាល់ដល់ជោគជ័យរបស់ FOs, និងគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ដែលត្រូវមានសម្រាប់ជំរុញការអភិវឌ្ឍ FOs នៅកម្ពុជា (Couturier *et al.* 2006; Nou 2006; Ngin 2010; Chea 2010)។ ការសិក្សាទាំងអស់នេះ បានប្រើវិធីសាស្ត្របែបគុណភាព ហើយបានផ្តល់នូវស្ថិតិបែបពណ៌នាមួយចំនួន។

អង្កេតមូលដ្ឋានមួយធ្វើឡើងដោយវិទ្យាស្ថាន CDRI នៅឆ្នាំ ២០១១ ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃ FOs ទៅលើសន្តិសុខស្បៀងរបស់ប្រជាជននៅជនបទកម្ពុជា បានបង្ហាញថា ការចូលរួមក្នុង FO មានផលប៉ះពាល់វិជ្ជមានទៅលើសន្តិសុខស្បៀងរបស់គ្រួសារនៅតាមជនបទ ឆ្លងតាមការល្អប្រសើរឡើងក្នុងផលិតភាពស្រូវ និងផលិតកម្មសត្វចិញ្ចឹម (CDRI 2012)[២]។ ការសិក្សានោះជាអង្កេតនៅចំណុចមួយនៃពេលវេលា និងមានគោលបំណងចម្បងកំណត់នូវបរិមាណនៃអថេរខ្លះ ក្នុងចំណោមប្រជាជនជាសំណាក ដោយប្រើវិធីសាស្ត្រ Propensity score matching (PSM)។ នៅឆ្នាំ២០១៣ អង្កេតតាមដានបន្តមួយបានអនុវត្តឡើងដើម្បីជួយបំពេញដល់ការសិក្សាវាយតម្លៃពីផលប៉ះពាល់។[៣] គោលបំណងនៃអង្កេតតាមដានបន្តនោះ គឺវាយតម្លៃឥទ្ធិពល FOs ទៅលើផលិតភាពរបស់កសិករខ្នាតតូច ដោយផ្អែកលើ ទិន្នផលស្រូវគិតជាគីឡូក្រាមក្នុងដីមួយហិកតាដែលបានប្រមូលផល និងប្រាក់ចំណូលពីការចិញ្ចឹមសត្វ (ជ្រូក និងមាន់)។

ការសិក្សានេះ ប្រើប្រាស់ទិន្នន័យបានពីអង្កេតតាមដានតាមពេលបន្តបន្ទាប់ ដើម្បីប៉ាន់ស្មានពីឥទ្ធិពល FOs ដោយប្រើវិធីប៉ាន់ស្មានពីភាពខុសគ្នាក្នុងភាពខុសគ្នា (Difference-in-differences (DiD) estimation) ។ ដោយប្រើបច្ចេកទេសនេះ យើងអាចកំណត់ថា តើ FOs មានឥទ្ធិពលខ្លាំងលើការបង្កើនផលិតភាពស្រូវ និងសត្វចិញ្ចឹមរបស់កសិករកម្ពុជា ជាពិសេសកសិករខ្នាតតូច ដែរឬទេ។

ការសិក្សានេះរួមចំណែកបានពីរយ៉ាង ក្នុងការពង្រឹងចំណេះដឹងក្នុងផ្នែកនេះ។ ទី១ ដោយប្រើ DiD យើងបានវិភាគពីទំនាក់ទំនងរវាងសមាជិក FO នឹងផលិតភាពកសិកម្ម ។ ទី២ ដោយប្រើទិន្នន័យតាមពេលបន្តបន្ទាប់ យើងបានវិភាគពីប្រសិទ្ធភាព FOs ទៅលើជីវភាពនៅតាមជនបទកម្ពុជា ។ ការសិក្សានេះបានធ្វើការស្រាវជ្រាវបន្ថែមលើការសិក្សាពីមុនធ្វើឡើងដោយ CDRI នៅឆ្នាំ២០១១ (CDRI 2012)។ ខុសប្លែកពីទិន្នន័យលើចំណុចមួយនៃពេលវេលាដែលបានប្រើនៅក្នុងការសិក្សាពីមុន ការប្រើទិន្នន័យតាមពេលបន្តបន្ទាប់នេះ ផ្តល់នូវការប៉ាន់ស្មានដ៏ល្អពីឥទ្ធិពលនៃ FOs (Khandker *et al.* 2010)។

---

[១] រៀបរៀងដោយ ឈឹម ឈន់ និង កែវ សុជាតិ ជាអ្នកស្រាវជ្រាវ នៃកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៅ CDRI។ រិទ្ធី ឡុងឌី ជាមន្ត្រីត្រួតពិនិត្យ និងវាយតម្លៃនៅនាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ នៃក្រសួងអភិវឌ្ឍន៍ជនបទ។

[២] លទ្ធផលសិក្សាមួយចំនួនត្រូវបានបោះពុម្ពផ្សាយដោយ CDRI (Theng *et al.* 2011; Keo 2013), ហើយអាចរកបានក្នុង www.cdri.org.kh

[៣] អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះ USAID ចំពោះការទ្រទ្រង់ផ្នែកហិរញ្ញវត្ថុដ៏សប្បុរសដល់ការសិក្សាតាមដានបន្ត ដែលបានធ្វើឡើងនៅឆ្នាំ២០១៣។ អ្នកនិពន្ធសូមអរគុណផងដែរដល់ អ្នកបណ្តុះបណ្តាលនានា ដែលបានផ្តល់នូវវគ្គបណ្តុះបណ្តាល "វគ្គខ្លីស្តីពីការវាយតម្លៃកម្មវិធីសម្រាប់អ្នកវិជ្ជាជីវៈនៅពាក់កណ្តាលអាជីពផ្នែកកសិកម្ម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ" ជាពិសេសសាស្ត្រាចារ្យ Suvedi Murari ពី Michigan State University, USA។

តារាង១: ចំនួន FOs និងគ្រួសារត្រូវបានជ្រើសរើស គិតតាមខេត្ត

| ខេត្ត | ចំនួន FOs | | គ្រួសារត្រូវបានជ្រើសរើស | | |
|---|---|---|---|---|---|
| | សរុប | ត្រូវបានជ្រើសរើស | សមាជិក FO | មិនមែនសមាជិក FO | សរុប |
| កំពង់ធំ | 328 | 15 | 94 | 104 | 198 |
| បាត់ដំបង | 411 | 19 | 119 | 132 | 251 |
| ស្វាយរៀង | 573 | 13 | 72 | 83 | 155 |
| កំពត | 143 | 7 | 45 | 50 | 95 |
| សរុប | 1455 | 54 | 330 | 369 | 699 |

ប្រភព: CDRI 2012

## វិធីសាស្ត្រប៉ាន់ស្មាន

គោលដៅស្រាវជ្រាវរបស់យើង គឺវិភាគពីឥទ្ធិពលនៃការចូលរួមក្នុង FO ទៅលើផលិតភាពកសិកម្ម ជាពិសេសស្រូវនិងសត្វចិញ្ចឹម ដោយប្រើទិន្នន័យលើរយៈពេលពីរ បានពីអង្កេតមូលដ្ឋានក្នុងឆ្នាំ២០១១ និង អង្កេតបន្តក្នុងឆ្នាំ២០១៣។ យើងបានបែងចែកសំណាកគំរូពីរក្រុម: ក្រុមរងប្រព្រឹត្តិកម្ម ដែលមានកសិករជាសមាជិក FO, និងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល ដែលមានកសិករមិនបានចូលរួមក្នុង FO។ ដើម្បីវាយតម្លៃឥទ្ធិពលរបស់ FO យើងបានប្រើការប៉ាន់ស្មាន DiD។

ការប៉ាន់ស្មាន DiD គណនាពី ភាពខុសគ្នាជាមធ្យមនៃលទ្ធផលបានសង្កេតឃើញតាមពេលបន្តបន្ទាប់ សម្រាប់ក្រុមរងប្រព្រឹត្តិកម្ម និងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។ ក្រោយបានគិតបញ្ចូលនូវភាពខុសគ្នាបន្ថែមទៀត រវាងការប្រែប្រួលជាមធ្យមក្នុងលទ្ធផលរបស់ក្រុមទាំងពីរ យើងអាចកំណត់ ប្រសិទ្ធភាពប្រព្រឹត្តិកម្មបាន ពោលគឺ ផលប៉ះពាល់ប៉ាន់ស្មាននៃបញ្ហាកំពុងយកមកវាយតម្លៃ - ក្នុងករណីនេះ គឺ ឥទ្ធិពលនៃការចូលជាសមាជិក FOs។

## ទិន្នន័យ

ការសិក្សានេះប្រើទិន្នន័យប្រមូលបានពីគ្រួសារនៅឆ្នាំ២០១១ សម្រាប់ការវាយតម្លៃផលប៉ះពាល់គោល និងទិន្នន័យមួយសំណុំទៀតប្រមូលបានពីគ្រួសារដដែលនៅឆ្នាំ២០១៣ ដែលជាអង្កេតបន្ត។ អង្កេតទាំងពីរ បានប្រមូលព័ត៌មានអំពីសមាជិក FO និងគ្រួសារមិនមែនជាសមាជិក FO ដូចជា ស្ថានភាពផ្ទះសម្បែង, ទ្រព្យសម្បត្តិជាប់លាប់, កម្មសិទ្ធិដីធ្លី, ផ្ទៃដីប្រមូលផល, ទិន្នផលស្រូវ, សត្វចិញ្ចឹម, សកម្មភាពមិនមែនកសិកម្ម, ឥណទាន និងប្រាក់កម្ចី។ យើងបានធ្វើសម្ភាសន៍ទល់មុខគ្នាជាមួយ មេគ្រួសារ ប្តីឬប្រពន្ធរបស់មេគ្រួសារ ឬ សមាជិកគ្រួសារពេញវ័យផ្សេងទៀត។

អង្កេតគោល[៤] បានធ្វើឡើងក្នុងបួនខេត្ត គឺ កំពង់ធំ, បាត់ដំបង, ស្វាយរៀង និង កំពត។ ការជ្រើសរើសសំណាក បានធ្វើឡើងជាបីជំហាន។ ជំហានទី១ គឺ ការជ្រើសរើស FOs, ជំហានទី២ គឺ ការកំណត់ស្រុកជាគោលដៅក្នុងខេត្តនីមួយៗ (បីស្រុកក្នុងខេត្តបាត់ដំបង និងពីរៗស្រុកក្នុងខេត្តបីផ្សេងទៀត) និង ជំហានទី៣ គឺ ការជ្រើសរើសគ្រួសារ (តារាង ១)។

តារាង ២: ចំនួនគ្រួសារបានធ្វើសម្ភាសន៍ក្នុងខេត្តកំពត

| លក្ខណៈគ្រួសារ | អង្កេតគោល (2011) | អង្កេតតាមដានបន្ត (2013) |
|---|---|---|
| សមាជិក | 45 | 43 |
| មិនមែនសមាជិក | 47 | 43 |
| សរុប | 92 | 86 |

ប្រភព: ការគណនារបស់អ្នកនិពន្ធ

សម្រាប់ការសិក្សាតាមដានបន្តនេះ ដោយសារធនធានមានកម្រិត យើងបានជ្រើសយកតែខេត្តកំពតមួយប៉ុណ្ណោះ។ អង្កេតគោលឆ្នាំ២០១១ បានប្រើ Propensity score matching (PSM) ដើម្បីប្រៀបធៀប អថេរផលប្រយោជន៍ រវាងក្រុមរងប្រព្រឹត្តិកម្ម នឹងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។ វិធីសាស្ត្រនេះជ្រើសរើសក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល ដោយធ្វើការផ្គូរផ្គងអ្នកចូលរួម និងអ្នកមិនចូលរួម ផ្អែកលើមូលដ្ឋាននៃភាពស្រដៀងគ្នាក្នុងលក្ខណៈសំគាល់ដែលបានសង្កេតឃើញ។ ការប្រើប្រាស់ PSM គឺដើម្បីកាត់បន្ថយភាពលំអៀង និងការប្រែប្រួលខុសភាពដើមផ្សេងៗដែលអាចកើតមាន។ អថេរនានាបានជ្រើសយកមកប្រើប្រាស់ ដោយផ្អែកលើកត្តាកំណត់ផ្សេងៗនៃការចូលរួមក្នុង FOs ដែលរួមមានលក្ខណៈមេគ្រួសារ ធនធានដែលគ្រួសារមាន និងលក្ខណៈទីតាំងគ្រួសារ។ ការប្រើប្រាស់ PSM ក្នុងអង្កេតគោល ជួយធានាថា គ្រួសារក្នុងក្រុមទាំងពីរ មានលក្ខណៈអាចប្រៀបធៀបគ្នាបាន។ ដូចមានចុះក្នុង តារាង ២ យើងប្រើទិន្នន័យលើ ៩២ គ្រួសារក្នុងខេត្តកំពត ដើម្បីធ្វើវិភាគគោល ប៉ុន្តែ តំណាងរបស់ ៦ គ្រួសារ បានអវត្តមានក្នុងអំឡុងពេលធ្វើអង្កេតតាមដានបន្ត ធ្វើឱ្យយើងមានទិន្នន័យតែលើ ៨៦គ្រួសារ (៤៣គ្រួសារក្នុងមួយក្រុម)។

## លទ្ធផល

តារាង ៣ បង្ហាញនូវ លទ្ធផលស្ថិតិបែបពិពណ៌នា ពោលគឺ លក្ខណៈជាមូលដ្ឋាននៃទិន្នន័យនៃអង្កេតគោល និងអង្កេតតាមដានបន្ត។ ក្នុងចំណោមគ្រួសារត្រូវបានអង្កេត គ្រួសារមានបុរស

[៤] ដោយសារតែមិនមានបញ្ជី FOs នាបច្ចុប្បន្នភាព គេប្រើបញ្ជី FOs ដែលមានស្រាប់ក្នុងខេត្តទាំងបួន ជាគំរូសម្រាប់ ការស្ទង់មតិ (អង្កេត) ជាមូលដ្ឋាននេះ។

តារាង ៣: លក្ខណៈគ្រួសារ

| ការពិពណ៌នា | | អង្កេតគោល (2011) | | អង្កេតតាមដានបន្ត (2013) | |
|---|---|---|---|---|---|
| | | ប្រព្រឹត្តិកម្ម | ផ្ទៀងផ្ទាត់ | ប្រព្រឹត្តិកម្ម | ផ្ទៀងផ្ទាត់ |
| ភេទមេគ្រួសារ (%): | បុរស | 75.6 | 78.7 | 70.0 | 84.0 |
| | ស្ត្រី | 24.4 | 21.3 | 30.0 | 16.0 |
| អាយុមេគ្រួសារ (ឆ្នាំ) | | 47.0 | 46.0 | 50.0 | 49.0 |
| ឆ្នាំសិក្សាមេគ្រួសារ (ឆ្នាំ) | | 5.0 | 5.0 | 5.0 | 5.0 |
| ទំហំគ្រួសារ (នាក់) | | 4.0 | 5.0 | 4.0 | 5.0 |
| អត្រាអក្ខរកម្មខ្មែរ (%) | | 77.8 | 66.0 | 74.4 | 67.4 |
| ស្ថានភាពអាពាហ៍ពិពាហ៍ (%): | រៀបការ | 77.8 | 83.0 | 76.7 | 83.7 |
| | លែងលះ | 2.2 | 2.1 | 2.3 | 2.3 |
| | មេម៉ាយ/ពោះម៉ាយ | 20.0 | 14.9 | 20.9 | 14.0 |
| ប្រភពចំណូលគ្រួសារ (%): | សកម្មភាពកសិកម្ម | 77.8 | 91.5 | 65.1 | 60.5 |
| | សកម្មភាពអាជីវកម្ម | 8.9 | 0.0 | 9.3 | 7.0 |
| | ផ្សេងៗ | 13.3 | 8.5 | 25.6 | 32.6 |
| ស្ថានភាពផ្ទះសម្បែង (%): | ផ្ទះស្លឹក | 4.4 | 8.5 | 0.0 | 4.7 |
| | ផ្ទះឈើប្រក់ក្បឿង | 40.0 | 38.3 | 44.2 | 23.3 |
| | ផ្ទះឈើប្រក់ស័ង្កសី/ហ្វីប្រូស៊ីម៉ង់ត៍ | 51.1 | 53.2 | 53.5 | 72.1 |
| | ផ្ទះបេតុង / ឥដ្ឋ | 4.4 | 0.0 | 2.3 | 0.0 |
| ទឹកផឹក (%): | ស្នប់/អណ្ដូងខួង | 8.9 | 10.6 | 23.3 | 30.2 |
| | អណ្ដូងជីក | 20.0 | 34.0 | 20.9 | 32.6 |
| | ស្រះ/អូរ | 64.4 | 53.2 | 41.9 | 30.2 |
| | ទឹកភ្លៀង | 6.7 | 2.1 | 14.0 | 7.0 |
| ឥន្ធនៈចម្អិនអាហារ (%): | អុសប្រមូលបាន | 91.1 | 93.62 | 83.7 | 95.4 |
| | អុសទិញ | 2.2 | 4.26 | 4.7 | 2.3 |
| | ឧស្ម័ន | 6.7 | 2.13 | 9.3 | 2.3 |
| | ផ្សេងៗ | 0.0 | 0.0 | 2.3 | 0.0 |
| ចម្ងាយពីផ្ទះទៅផ្សារ (គ.ម) | | 1.3 | 1.0 | 1.3 | 1.0 |
| ទ្រព្យសម្បត្តិគ្រួសារ (ម៉ឺនរៀល, ចារីក) | | 842.6 | 645.9 | 978.9 | 757.9 |

ប្រភព: ការគណនារបស់អ្នកនិពន្ធ

ជាមេគ្រួសារមានច្រើនជាងគេក្នុងក្រុមទាំងពីរ។ ក្នុងអង្កេតគោល និងអង្កេតតាមដានបន្ត ភាគរយគ្រួសារមានស្ត្រីជាមេគ្រួក្នុងក្រុមរងប្រព្រឹត្តិកម្ម (សមាជិក FO) មានចំនួនច្រើនជាងក្នុងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។

បើគិតពីចំនួនឆ្នាំសិក្សារបស់មេគ្រួសារវិញ គ្មានការខុសគ្នាទេរវាងក្រុមរងប្រព្រឹត្តិកម្ម នឹងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើលពោលគឺ ពួកគេបានទទួលការអប់រំត្រឹមកម្រិតបឋមសិក្សាចំនួនប្រាំឆ្នាំដូចគ្នា។ គេឃើញមានការខុសគ្នាតិចតួច ក្នុងទំហំគ្រួសារនៃក្រុមរងប្រព្រឹត្តិកម្ម (៤នាក់) និងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល (៥នាក់)។ ហើយតួលេខខុសគ្នានេះនៅដដែល ក្នុងពេលធ្វើការសិក្សាគោល និងការសិក្សាតាមដានបន្ត។ កម្រិតអក្ខរកម្មខ្មែរ (សមត្ថភាពអានអត្ថបទខ្មែរ) ខុសគ្នាបន្តិចរវាងឆ្នាំ២០១១ នឹង ២០១៣៖ នៅឆ្នាំ២០១១ មាន ៧៧,៨% សម្រាប់ក្រុមរងប្រព្រឹត្តិកម្ម និង ៦៦%សម្រាប់ក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល រីឯនៅឆ្នាំ២០១៣ មាន ៧៤,៤%សម្រាប់ក្រុមរងប្រព្រឹត្តិកម្ម និង ៦៧,៤% សម្រាប់ក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។ មេគ្រួសារច្រើនជាង ៧៦,៧% ទាំងនៅឆ្នាំ២០១១ និងឆ្នាំ២០១៣ បានបញ្ជាក់ថាពួកគេមានប្រពន្ធ/ប្ដី។ លទ្ធផលបង្ហាញទៀតថា មានអត្រាស្ត្រីមេម៉ាយ/បុរសពោះម៉ាយខ្ពស់ ក្នុងចំណោមអ្នកចូលរួម គឺមាន មេគ្រួសារ ២០% ក្នុងក្រុមរងប្រព្រឹត្តិកម្ម និង ១៤% ក្នុងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។

តួនាទីកសិកម្មជាប្រភពប្រាក់ចំណូលរបស់គ្រួសារ បានប្រែប្រួលខ្លះៗក្នុងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល ពី ៧៧,៨% នៅឆ្នាំ២០១១ ដល់ ៦៥,១% នៅឆ្នាំ២០១៣ រីឯក្នុងក្រុមរងប្រព្រឹត្តិកម្ម វាបានថយចុះប្រហែលមួយភាគបី ពី ៩១,៥% នៅឆ្នាំ២០១១ ដល់ ៦០,៥% នៅឆ្នាំ២០១៣។ តួលេខនេះបង្ហាញថា កសិករបាននិងកំពុងគិតគូរធ្វើសកម្មភាពអាជីវកម្មផ្សេងទៀតក្រៅពីការធ្វើកសិកម្ម។ លទ្ធផលអង្កេតពីស្ថានភាពផ្ទះសម្បែងបង្ហាញថា ភាគរយគ្រួសាររងប្រព្រឹត្តិកម្មដែលរស់នៅក្នុងផ្ទះឈើប្រក់ក្បឿង ឬប្រក់ស័ង្កសី ឬហ្វីប្រូស៊ីម៉ង់ត៍ បានកើនឡើងបន្តិច

រវាងអង្កេតគោល នឹងអង្កេតតាមដានបន្ត។ ផ្ទុយទៅវិញ តួលេខលើក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល បានបង្ហាញនូវការប្រែប្រួលថយចុះគុណភាពផ្ទះសម្បែង ដោយ ផ្ទះឈើប្រក់ក្បឿងបានថយចុះ ១៥% ហើយផ្ទះឈើប្រក់ស័ង្កសីបានកើនឡើង ១៩% រវាងអង្កេតគោល នឹងអង្កេតតាមដានបន្ត។ ចំពោះបញ្ហាទឹកផឹក ក្នុងអង្កេតគោល ភាគរយគ្រួសារប្រើទឹកស្រះ/អូរ មានកម្រិតខ្ពស់ដល់ ៦៤,៤% ក្នុងក្រុមរងប្រព្រឹត្តិកម្ម និង ៥៣,២% ក្នុងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។ ប៉ុន្តែក្នុងអង្កេតតាមដានបន្តនៅឆ្នាំ២០១៣ តួលេខនេះបានថយចុះគួរឱ្យកត់សម្គាល់ ដល់ ៤១,៩% និង ៣០,២% រៀងគ្នា។ ក្នុងពេលជាមួយគ្នា ការប្រើប្រាស់ទឹកភ្លៀងក្នុងក្រុមរងប្រព្រឹត្តិកម្មបានកើនឡើងស្ទើរមួយជាពីរ ដល់ ១៤,០% រីឯក្នុងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល វាបានកើនលើសពីមួយជាបី គឺរហូតដល់ ៧,០%។ ការប្រើស្នប់/អណ្តូងខួង បានកើនឡើងច្រើន ប្រហែល ២,៥ដង (២៣,៣%) ក្នុងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល និងកើនស្ទើរបីដង (៣០,២%) សម្រាប់ក្រុមរងប្រព្រឹត្តិកម្ម។ អុសប្រមូលបាន ជាប្រភពថាមពលដ៏សំខាន់សម្រាប់ចម្អិនអាហារ (ពី ៨៣% ទៅ ៩៥%) ទោះបីវាបានថយចុះអស់ ៧% ក្នុងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល នៅពេលធ្វើអង្កេតតាមដានបន្តក្តី។

ចម្ងាយពីផ្ទះទៅផ្សារធំ វាខុសគ្នាតិចតួចទេរវាងក្រុមរងប្រព្រឹត្តិកម្ម នឹងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល និងគ្មានប្រែប្រួលទេរវាងអង្កេតគោល នឹងអង្កេតតាមដានបន្ត ពោលគឺ ១,៣គ.ម សម្រាប់ក្រុមរងប្រព្រឹត្តិកម្ម និង ១គ.ម សម្រាប់ក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។ ទ្រព្យសម្បត្តិគ្រួសារកើនពី ៨៤២,៦ម៉ឺនរៀល ដល់ ៩៧៨,៩ម៉ឺនរៀល សម្រាប់ក្រុមរងប្រព្រឹត្តិកម្ម និងពី ៦៤៥,៩ម៉ឺនរៀល ដល់ ៧៥៧,៩ម៉ឺនរៀល សម្រាប់ក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។ ប៉ុន្តែកំណើននេះមិនមានឥទ្ធិពលខ្លាំង ទៅលើជីវភាពរស់នៅរបស់គ្រួសារទាំងនោះទេ ដោយសារ T-តេស្ត (ការពិនិត្យស្ថិតិ) មានបង្ហាញលទ្ធផលមិនសំខាន់។

លទ្ធផលនៃការប៉ាន់ស្មានតាម DiD មានបង្ហាញក្នុង តារាង ៤។ លទ្ធផលនេះបានពីអថេរសម្រាប់ផ្ទៀងផ្ទាត់មើល ដូចមានចុះក្នុងតារាង ៥ ក្នុងឧបសម្ព័ន្ធនេះ។ ការគណនា DiD ជាផលបូកដកបានពីអថេរនៃស្រូវអង្ករទាំងអស់ - ទិន្នផល ការប្រើប្រាស់ ការលក់ ប្រាក់ចំណូលសរុប និងប្រាក់ចំណេញសុទ្ធ។ ទោះយ៉ាងនេះក្តី ស្ថិតិ T-តេស្ត បង្ហាញថា គ្មានអថេរលទ្ធផលណាមួយមានសារៈសំខាន់ខាងស្ថិតិទេ ដែលមានន័យថា FOs មិនមានផលប៉ះពាល់វិជ្ជមានគួរឲ្យកត់សំគាល់ទៅលើ ផលិតភាពស្រូវរបស់សមាជិក FO នោះទេ។

លទ្ធផលរបស់គ្រួសារចិញ្ចឹមមាន់ (៩២គ្រួសារក្នុងអង្កេតគោល និង ៧៨គ្រួសារក្នុងអង្កេតតាមដានបន្ត) បង្ហាញភាពខុសគ្នាអវិជ្ជមានសម្រាប់អថេរ ចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ ការលក់ និងការលក់ក្នុងមនុស្សម្នាក់ ដូចមានបង្ហាញក្នុងជួរឈរ DiD។ តួលេខនេះបញ្ជាក់ថា លទ្ធផលក្នុងអង្កេតតាមដានបន្ត វាទាបជាងលទ្ធផលក្នុងអង្កេតគោល។ លទ្ធផល T-តេស្ត (តម្លៃ P - ប្រូបាប៊ីលីតេដែល លទ្ធផលនៃការសិក្សានេះវាកើតមានឡើង

តារាង ៤: លទ្ធផល Difference-in-Differences ( kernel-based propensity score applied )

| | អង្កេតគោល (2011) | | | អង្កេតតាមដានបន្ត (2013) | | | | |
|---|---|---|---|---|---|---|---|---|
| អថេរលទ្ធផល | ផ្ទៀងផ្ទាត់មើល | រងប្រព្រឹត្តិកម្ម | ភាពខុសគ្នា | ផ្ទៀងផ្ទាត់មើល | រងប្រព្រឹត្តិកម្ម | ភាពខុសគ្នា | DiD | តម្លៃ-p |
| **ស្រូវ:** | | | | | | | | |
| ទិន្នផល (គ.ក/ហិកតា) | 1978.4 | 2401.6 | 423.2 | 1891.3 | 1996.8 | 105.4 | -317.8 | (0.46) |
| ចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ (គ.ក) | 1090.5 | 1401.2 | 310.7 | 757.5 | 1016.3 | 258.8 | -51.9 | (0.82) |
| ការលក់ /ហិកតា (គ.ក) | 311.1 | 499.4 | 188.3 | 387.1 | 546.3 | 159.1 | -29.1 | (0.94) |
| ប្រាក់ចំណូលសរុប (ម៉ឺនរៀល) | 31.0 | 50.6 | 19.6 | 31.1 | 35.6 | 4.5 | -15.1 | (0.59) |
| ប្រាក់ចំណេញសុទ្ធ/ហិកតា(ម៉ឺនរៀល) | 117.2 | 200.3 | 83.1 | 119.4 | 129.0 | 9.6 | -73.5 | (0.13) |
| **មាន់:** | | | | | | | | |
| ផលិតកម្មក្នុងមនុស្សម្នាក់ (គ.ក) | 4.7 | 11.5 | 6.8 | 3.0 | 12.4 | 9.3 | 2.6 | (0.55) |
| ចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ (គ.ក) | 1.6 | 3.6 | 2.0 | 0.8 | 2.0 | 1.2 | -0.8 | (0.50) |
| ការលក់ (គ.ក) | 1.4 | 4.2 | 2.8 | 0.6 | 2.4 | 1.9 | -0.9 | (0.56) |
| ការលក់ក្នុងមនុស្សម្នាក់ (ម៉ឺនរៀល) | 1.7 | 5.5 | 3.8 | 0.9 | 3.6 | 2.7 | -1.1 | (0.62) |
| **ជ្រូក:** | | | | | | | | |
| ផលិតកម្មក្នុងមនុស្សម្នាក់ (គ.ក) | 22.7 | 31.8 | 9.2 | 9.0 | 27.6 | 18.7 | 9.5 | (0.58) |
| ចំណាយប្រើប្រាស់/១ក្បាល (គ.ក) | 0.0 | 1.1 | 1.1 | 0.0 | 0.4 | 0.4 | -0.7 | (0.64) |
| ការលក់ (គ.ក) | 14.4 | 18.4 | 4.0 | 5.8 | 22.7 | 16.9 | 12.9 | (0.36) |
| ការលក់ក្នុងមនុស្សម្នាក់ (ម៉ឺនរៀល) | 13.9 | 16.9 | 3.0 | 5.1 | 23.9 | 18.8 | 15.8 | (0.40) |

ប្រភព: ការគណនារបស់អ្នកនិពន្ធ

ដោយចៃដន្យ) បង្ហាញថា ភាពខុសគ្នានេះមិនមានសារៈសំខាន់ខាងស្ថិតិទេ។ តាមលទ្ធផលស្ថិតិ T-តេស្ត យើងអាចដឹងថា ការចូលរួម FOs មិនមានឥទ្ធិពលលើផលិតភាពចិញ្ចឹមមាន់របស់កសិករទេ។

សម្រាប់ការចិញ្ចឹមជ្រូក គឺមាន ៧៧គ្រួសារក្នុងអង្កេតគោល និង ៥៥គ្រួសារក្នុងអង្កេតតាមដានបន្ត។ លទ្ធផលក្នុងជួរឈរ DiD មានតួលេខអវិជ្ជមានសម្រាប់ចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ ប៉ុន្តែមានតួលេខវិជ្ជមានសម្រាប់ ការលក់ ផលិតកម្មក្នុងមនុស្សម្នាក់ និងការលក់ក្នុងមនុស្សម្នាក់។ ទោះយ៉ាងនេះក្ដី សម្រាប់អថេរទាំងអស់ តួលេខមិនមានសារៈសំខាន់ខាងស្ថិតិទេ។ ដូច្នេះយើងអាចសន្និដ្ឋានថា ការចូលរួមក្នុង FOs មិនមានឥទ្ធិពលអ្វីលើផលិតភាពការចញ្ចឹមជ្រូករបស់កសិករក្នុងអង្កេតទេ។

## សេចក្ដីសន្និដ្ឋាន

លទ្ធផលការសិក្សាគោលរបស់CDRIនៅឆ្នាំ២០១១បង្ហាញថា ការចូលរួមក្នុង FO មានផលប៉ះពាល់វិជ្ជមានលើសន្តិសុខស្បៀងគ្រួសារនៅតាមជនបទ ឆ្លងតាមការល្អប្រសើរឡើងក្នុងផលិតភាពស្រូវនិង ផលិតកម្មសត្វចិញ្ចឹម។ ការសិក្សានេះផ្អែកលើអង្កេតធ្វើឡើងនៅចំណុចមួយនៃពេលវេលា។ ប៉ុន្តែតាមការប្រើទិន្នន័យតាមពេលបន្តបន្ទាប់បានពី អង្កេតតាមដានបន្ត និងផ្ដោតលើខេត្តកំពតតែមួយខេត្ត យើងបានរកឃើញថា ការចូលរួមក្នុង FOs មិនមានផលប៉ះពាល់ទៅលើផលិតកម្មស្រូវនិងផលិតភាពសត្វចិញ្ចឹមទេ។ ការសិក្សានេះ ផ្ដល់ការសន្និដ្ឋានថា FOs មិនមានឥទ្ធិពលខ្លាំងលើផលិតភាពស្រូវ និងសត្វចិញ្ចឹមរបស់គ្រួសារនៅជនបទ ក្នុងខេត្តកំពតទេ។ ដោយសារសំណាកមានទំហំតូច ដូច្នេះលទ្ធផលទាំងនេះគួរសិក្សាស្រាវជ្រាវបន្ថែមទៀត។

## ឯកសារយោង:


Abaru, M.B., A. Nyakuni and G. Shone (2006), *Strengthening Farmers Organisations: RELMA's Experience in Eastern and Southern Africa*, ICRAF Working Paper No. 23 (Nairobi: World Agroforestry Centre)

Bachke, M.E. (2010), *Do Farmers' Organizations Enhance the Welfare of Small-Scale Farmers?* Working Paper (As, Norway: Norwegian University of Life Sciences)

Barham, J. and C. Chitemi (2007), *Collective Action Initiatives to Improve Marketing Performance*: Lessons from Farmer Groups in Tanzania, CAPRi Working Paper No. 74 (Washington, DC: IFPRI)

Bingen, J., A. Serrano and J. Howard (2003), "Linking Farmer to Market: Different Approaches to Human Capital Development", *Food Policy,* 28, pp. 405-419

CDRI, Cambodia Development Resource Institute (2012), " Impact Assessment of Farmer Organisations on Food Security for the Rural Poor", unpublished report (Phnom Penh: CDRI)

Couturier, J., S.O. Savun and P. Ham (2006), "Inventory of Farmer Organisations in Cambodia", draft prepared for Office of Farmer Organisation,Department of Agricultural Extension, Ministry of Agriculture, Forestry and Fisheries, Phnom Penh

Chea S. (2010), "Final Report on Policy Analysis for Farmer Organisation Development, Department of Agricultural Extension" (Phnom Penh: MAFF, sponsored by IFAD and FAO)

Chirwa, E., A. Dorward, R. Kachule, I. Kumwenda, J. Kydd, N. Poole, C. Poulton and M. Stockbridge (2005), "Walking Tightropes: Supporting Farmer Organisations for Market Access", *Natural Resource Perspective* (London: Overseas Development Institute)

Keo S. (2013), "Gender Inequality in Agriculture: A Household Survey of Farmer Organisations in Four Provinces", *Cambodia Development Review*, Vol. 17 (Phnom Penh: CDRI) pp. 13-18

Khandker, Shahidure R., Gayatri B. Koolwal and Hussain A. Samad (2010), *Handbook on Impact Evaluation: Quantitative Methods and Practices* (Washington, DC: World Bank)Ngin C. (2010)," Farmers' Associations in Cambodia: Internal Functions and External Relations", RCSD Research Report (Chiang Mai: Regional Center for Social Science and Sustainable Development)

Nou Keosothea (2006), "Emerging Structure of Agricultural Cooperative in Cambodia", *Cambodia Development Review* (Phnom Penh: CDRI)

Peacock, C., A. Jowett, A. Dorward, C. Poulton and I. Urey (2004), "Reaching the Poor: A Call to Action – Investment in Small Agriculture in Sub-Saharan Africa", unpublished report for FARMAfrica (London: Imperial College)

Schlotter, M., G. Schwerdt and L. Woessmann (2011), "Econometric Methods for Causal Evaluation of Education Policies and Practices: A Non-technical Guide" *Education Economics*, 19(2), 109-137

Theng V., Nou K., Keo S., Sum S. and Khiev P. (2011)," Farmer Organisations in Cambodia: Do they Improve Food Security of the Rural Poor?" *Cambodia Development Review*, Vol. 15 (Phnom Penh: CDRI) pp. 13-17

World Bank (2005), *Cambodia Rural Sector Strategy Note: Towards a Strategy for Rural Growth and Poverty Reduction* (Washington, DC: World Bank)

World Bank (2009a), *Poverty Profile and Trend in Cambodia: Findings from the 2007 CSES* (Phnom Penh: World Bank)

## ឧបសម្ព័ន្ធ

តារាង៥. បញ្ជីអថេរសម្រាប់ផ្ទៀងផ្ទាត់មើល (covariates) ក្នុងការប៉ាន់ស្មាន Difference-in-Differences

| អថេរ | ការពិពណ៌នា | 2011 | | | 2013 | | |
|---|---|---|---|---|---|---|---|
| | | ចំនួន (Obs) | មធ្យម (Mean) | គម្លាតស្តង់ដា | ចំនួន (Obs) | មធ្យម (Mean) | គម្លាតស្តង់ដា |
| q1_31 | សកម្មភាពកសិកម្ម (dummy គឺ មាន=១, អត់=0)) | 92 | 0.85 | 0.36 | 86 | 0.63 | 0.49 |
| q1_32 | សកម្មភាពអាជីវកម្ម (dummy) | 92 | 0.04 | 0.21 | 86 | 0.08 | 0.28 |
| q2_1_22 | ផ្ទះឈើប្រក់ក្បឿង (dummy) | 92 | 0.39 | 0.49 | 86 | 0.34 | 0.48 |
| q2_1_23 | ផ្ទះឈើប្រក់ស័ង្កសី/ហ្វីប្រូស៊ីម៉ង់ត៍ (dummy) | 92 | 0.52 | 0.50 | 86 | 0.63 | 0.49 |
| q2_1_24 | ផ្ទះបេតុង / ឥដ្ឋ (dummy) | 92 | 0.02 | 0.15 | 86 | 0.01 | 0.11 |
| q2_1_42 | អណ្តូងជីក (dummy) | 92 | 0.27 | 0.45 | 86 | 0.27 | 0.45 |
| q2_1_43 | ស្រះ/អូរ (dummy) | 92 | 0.59 | 0.50 | 86 | 0.36 | 0.48 |
| q2_1_44 | ទឹកភ្លៀង (dummy) | 92 | 0.04 | 0.21 | 86 | 0.10 | 0.31 |
| q2_1_51 | អុសប្រមូលបាន (dummy) | 92 | 0.92 | 0.27 | 86 | 0.90 | 0.31 |
| q2_1_53 | ឧស្ម័ន (dummy) | 92 | 0.04 | 0.21 | 86 | 0.06 | 0.24 |
| q2_1_61 | អគ្គិសនីក្រុង (dummy) | 92 | 0.00 | 0.00 | 86 | 0.07 | 0.26 |
| q2_1_62 | ម៉ាស៊ីនភ្លើង (dummy) | 92 | 0.02 | 0.15 | 86 | 0.00 | 0.00 |
| q2_1_63 | ប្រេងកាត/ប្រេងសាំង (dummy) | 92 | 0.33 | 0.47 | 86 | 0.10 | 0.31 |
| q2_1_64 | ទៀន (dummy) | 92 | 0.01 | 0.10 | 86 | 0.01 | 0.11 |
| q2_1_65 | អាគុយ/ពិល (dummy) | 92 | 0.62 | 0.49 | 86 | 0.74 | 0.44 |
| q2_1_67 | (សូមបញ្ជាក់) (dummy) | 92 | 0.02 | 0.15 | 86 | 0.01 | 0.11 |
| q2_1_71 | បង្គន់ខ្លួនឯង (dummy) | 92 | 0.18 | 0.39 | 86 | 0.22 | 0.42 |
| q1_2_31 | ភេទ (បុរស=1) | 92 | 0.77 | 0.42 | 86 | 0.77 | 0.42 |
| q1_2_61 | អក្ខរកម្ម (មាន=1) | 92 | 0.72 | 0.45 | 86 | 0.71 | 0.46 |
| q1_2_71 | មានប្តី/ប្រពន្ធ (dummy) | 92 | 0.80 | 0.40 | 86 | 0.80 | 0.40 |
| q1_2_73 | មេម៉ាយ/ពោះម៉ាយ (dummy) | 92 | 0.17 | 0.38 | 86 | 0.17 | 0.38 |
| q1_2_92 | ការងារកសិកម្ម (លក់កម្លាំងពលកម្មក្នុងភូមិ) (dummy) | 92 | 0.01 | 0.10 | 86 | 0.01 | 0.11 |
| q1_2_93 | ធ្វើការក្រៅភូមិក្នុងប្រទេស (dummy) | 92 | 0.04 | 0.21 | 86 | 0.05 | 0.21 |
| q1_2_94 | ចំណាកស្រុកទៅធ្វើការនៅទល់ដែន (dummy) | 92 | 0.01 | 0.10 | 86 | 0.01 | 0.11 |
| q1_2_95 | ធ្វើការនៅប្រទេសដទៃ (dummy) | 92 | 0.02 | 0.15 | 86 | 0.02 | 0.15 |
| q1_2_96 | មន្ត្រីរាជការ/បុគ្គលិក NGOs/បុគ្គលិកក្រុមហ៊ុន (dummy) | 92 | 0.07 | 0.25 | 86 | 0.07 | 0.26 |
| q1_2_97 | អាជីវកម្មខ្នាតតូច/ អាជីវកម្មខ្នាតតូចរួមគ្នា (dummy) | 92 | 0.26 | 0.44 | 86 | 0.28 | 0.45 |
| q1_2_98 | ធនធានប្រមូលបានពីទឹក ឬ ដី(dummy) | 92 | 0.05 | 0.23 | 86 | 0.05 | 0.21 |
| q1_2_99 | ធ្វើការសំណង់ (dummy) | 92 | 0.16 | 0.37 | 86 | 0.14 | 0.35 |
| q1_2_910 | ចងការប្រាក់ (dummy) | 92 | 0.02 | 0.15 | 86 | 0.02 | 0.15 |
| q1_2_911 | សិប្បកម្ម (dummy) | 92 | 0.02 | 0.15 | 86 | 0.02 | 0.15 |
| q1_2_912 | លក់កម្លាំងពលកម្មក្នុងភូមិ(សកម្មភាពមិនមែនកសិកម្ម) (dummy) | 92 | 0.01 | 0.10 | 86 | 0.01 | 0.11 |
| q1_2_4 | អាយុមេគ្រួសារ | 92 | 46.64 | 13.13 | 86 | 47.29 | 13.19 |
| q1_2_8 | កម្រិតអប់រំ (ចំនួនឆ្នាំសិក្សា) របស់មេគ្រួសារ | 92 | 5.23 | 3.72 | 86 | 5.26 | 3.80 |

ប្រភព: ការគណនារបស់អ្នកនិពន្ធ